**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខៈ ៣៧៧/០៨**

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចការងារវប្បធម៌និងវិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ស្រុកខណ្ឌ ។

## សម្រេច

**ប្រការ១ .-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចការងារវប្បធម៌និងវិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញក្នុងក្របខណ្ឌនៃការចេញអាជ្ញាបណ្ណ ដើម្បីផ្តល់សេវាកម្មវប្បធម៌និងវិចិត្រសិល្បៈដូចខាងក្រោម៖

- កម្មវិធីសម្តែងសិល្បៈផ្សេងៗ
- កម្មវិធីបញ្ចាំងភាពយន្ត វីដេអូ
- សេវាកម្មលក់ ជួលស្នាដៃភាពយន្ត វីដេអូ
- សេវាកម្មផ្តិតរូប ថតរូប ថតវីដេអូ
- សេវាកម្មស្លាកសញ្ញាអាជីវកម្ម
- សេវាកម្មចម្លាក់ពុម្ព
- សេវាកម្មលក់សៀវភៅ
- សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ

ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

- សេវាកម្មគ្រឿងបំពងសំឡេង
- សេវាកម្មអ៊ិតសក់ កាត់សក់ លម្អក្រចក និង
- សេវាកម្មសម្អាងការ

**ប្រការ២ .–**

មន្ត្រីទទួលបន្ទុកបច្ចេកទេសជំនាញនិងនីតិកម្ម ត្រូវរៀបចំគំរូសំណុំបែបបទ តាមគោលការណ៍កំណត់ ជូនខណ្ឌគោលដៅសម្រាប់ការផ្តល់អាជ្ញាបណ្ណសេវាកម្ម ដូចបានចែងក្នុងប្រការ ១ ។

**ប្រការ៣ .–**

ការអនុវត្តលើសំណុំបែបបទ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាបណ្ណសេវាកម្ម វប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

បញ្ជីលម្អិតរាយមុខសេវាកម្ម ដែលត្រូវធ្វើប្រតិភូកម្មជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ ជាឧបសម្ពន្ធនៃប្រកាសនេះ ។

**ប្រការ៤ .–**

ខណ្ឌគោលដៅ ត្រូវធ្វើរបាយការណ៍រៀងរាល់ខែនិងឆ្នាំពីលទ្ធផលនៃសកម្មភាពផ្តល់អាជ្ញាបណ្ណសេវាកម្ម វប្បធម៌ និងវិចិត្រសិល្បៈតាមរយៈមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី មកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

**ប្រការ៥ .–**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ និង មន្ត្រីទទួលបន្ទុកការងារវិសហមជ្ឈការ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
(ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល)
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
(អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)
- សាលារាជធានីភ្នំពេញ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ពន្ធ ប្រកាសលេខ ៣៩/វបក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ស្តីពីការធ្វើប្រតិភូកម្មមុខងារ
និងភារកិច្ចការងារវប្បធម៌និងវិចិត្រសិល្បៈជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ
បញ្ជីលម្អិតរាយមុខសេវាកម្មវប្បធម៌និងវិចិត្រសិល្បៈ

| ល.រ | សេវាកម្ម | ប្រភេទសេវាកម្ម | ផ្សេងៗ |
|---|---|---|---|
| ១ | -កម្មវិធីសម្តែងសិល្បៈផ្សេងៗ | - ការប្រគំតន្ត្រីតាមទីសាធារណ:<br>- ការសម្តែងល្ខោនគ្រប់ទម្រង់ (លក់សំបុត្រ)<br>- អាជីវកម្មរាំលក់ផ្កា | (២កម្រិត) |
| ២ | -កម្មវិធីបញ្ចាំងភាពយន្តវីដេអូ | - បញ្ចាំងផ្សព្វផ្សាយពាណិជ្ជកម្ម (តាមទីសាធារណ:)<br>- បញ្ចាំងកំដរក្នុងពិធីបុណ្យផ្សេងៗ (តាមទីសាធារណ:)<br>- បញ្ចាំងកំដរភ្ញៀវ( ហាងកាហ្វេ ក្លិបកំសាន្ត ។ល។ ) | (ចល័ត)<br>(ចល័ត) |
| ៣ | -សេវាកម្មលក់ជួលស្នាដៃ ភាពយន្ត វីដេអូ | - អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី<br>- ហាងលក់ ជួលកាស្សែត ស៊ីឌី វីស៊ីឌី ឌីវីឌី<br>- តូបលក់ជួលកាស្សែត ស៊ីឌី វីស៊ីឌី ឌីវីឌី | |
| ៤ | -សេវាកម្មផ្តិតរូប ថតរូបនិង ថតវីដេអូ | - អគារផ្តិតរូប ថតរូប ថតវីដេអូ (ស្ទូឌីយោ)<br>- ហាងថតរូប ថតវីដេអូ | |
| ៥ | - សេវាកម្មស្លាកសញ្ញា អាជីវកម្ម | - ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និង និមិត្តសញ្ញាផ្សេងៗ<br>- បដាផ្សាយពាណិជ្ជកម្ម<br>- បណ្ណប្រកាសផ្សាយពាណិជ្ជកម្ម<br>- ទីតាំងផលិតស្លាកសញ្ញា<br>- ជាងគំនូរ | (៥កម្រិត) |
| ៦ | -សេវាកម្មចម្លាក់ពុម្ព | - ទីតាំងផលិត លក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍<br>- ទីតាំងផលិតលក់ចម្លាក់ម្នាងសិលា | |
| ៧ | -សេវាកម្មលក់សៀវភៅ | - បណ្ណាគារ<br>- តូបលក់សៀវភៅ | (២កម្រិត) |
| ៨ | -សេវាកម្មបញ្ចូលបទភ្លេង ទូរស័ព្ទ | -សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ | |
| ៩ | -សេវាកម្មគ្រឿងបំពង សំឡេង | - សេវាកម្មជួលឧគ្ឃោសនសព្ទក្នុងពិធីផ្សេងៗ<br>- សេវាកម្ម ជួលធុងបាស់ | |
| ១០ | -សេវាកម្មអ៊ុតសក់ កាត់សក់ លម្អក្រចក | - អ៊ុតសក់ កាត់សក់ លម្អក្រចក<br>- កាត់សក់ | (២កម្រិត) |
| ១១ | -សេវាកម្មសម្អាងការ | - សម្អាងការ | (៣កម្រិត) |

# តារាងតម្លៃសេវាកម្មវប្បធម៌និងវិចិត្រសិល្បៈ
# ដែលត្រូវធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ

| លក្ខណៈប្រតិភូកម្ម | មុខសេវាកម្ម | | តម្លៃសេវាកម្ម | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|
| | | | បង្កាន់ដៃ - ពាក្យសុំ | តែមប្រ៍ | សេវាប្រតិបត្តិ | រយៈពេល | អាជ្ញាបណ្ណ | |
| ១-កម្មវិធីសម្តែងសិល្បៈផ្សេងៗ | -ការប្រគំតន្ត្រីតាមទីសាធារណៈ: | លក្ខណៈអន្តរជាតិ | ១០០០៛ | ២០០០៛ | ១៩៧០០០៛ | ១លើក | លិខិតអនុញ្ញាត | ២០០០០០៛ |
| | | លក្ខណៈជាតិ | ១០០០៛ | ២០០០៛ | ៩៧០០០៛ | | | ១០០០០០៛ |
| | -ការសម្តែងល្ខោនគ្រប់ទម្រង់(លក់សំបុត្រ) | | ១០០០៛ | ២០០០៛ | ១២០០០៛ | | | ១៥០០០៛ |
| | -អាជីវកម្មរាំលក់ផ្កា (លក់សំបុត្រ) | | ១០០០៛ | ២០០០៛ | ១២០០០៛ | ១ថ្ងៃ | | ១៥០០០៛ |
| ២-កម្មវិធីបញ្ចាំងភាពយន្តវីដេអូ | -បញ្ចាំងផ្សព្វផ្សាយពាណិជ្ជកម្ម | | ១០០០៛ | ២០០០៛ | ១២០០០៛ | ១ថ្ងៃ | លិខិតអនុញ្ញាត | ១៥០០០៛ |
| | -បញ្ចាំងកំដរក្នុងពិធីបុណ្យផ្សេងៗ | | ១០០០៛ | ២០០០៛ | ១២០០០៛ | | | ១៥០០០៛ |
| | -បញ្ចាំងកំដរភ្ញៀវ | | ៣០០០៛ | ២០០០៛ | ២១០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ២៦០០០៛ |
| ៣-សេវាកម្មលក់ជួលស្នាដៃភាពយន្តវីដេអូ | -អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី | | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | -ហាងលក់ ជួលកាស្សែត ស៊ីឌី វីស៊ីឌី ឌីវីឌី | | ៣០០០៛ | ២០០០៛ | ២១០០០៛ | | | ២៦០០០៛ |
| | -តូបលក់ជួលកាស្សែត ស៊ីឌី វីស៊ីឌី ឌីវីឌី | | ៣០០០៛ | ២០០០៛ | ១២០០០៛ | | | ១៧០០០៛ |
| ៤-សេវាកម្មផ្តិតរូប ថតរូបនិងថតវីដេអូ | -អគារផ្តិតរូប ថតរូប ថតវីដេអូ ( ស្ទូឌីយោ ) | | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | -ហាងថតរូប ថតវីដេអូ | | ៣០០០៛ | ២០០០៛ | ២១០០០៛ | | | ២៦០០០៛ |
| ៥-សេវាកម្មស្លាកសញ្ញាអាជីវកម្ម | -ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និង និមិត្តសញ្ញាផ្សេង ៗ | ២ម$^{២}$ ចុះក្រោម | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ២ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | | ២ម$^{២}$ - ៤ម$^{២}$ | ៣០០០៛ | ២០០០៛ | ៤៥០០០៛ | | | ៥០០០០៛ |
| | | ៤ម$^{២}$ - ៨ម$^{២}$ | ៣០០០៛ | ២០០០៛ | ៩៥០០០៛ | | | ១០០០០០៛ |
| | | ៨ម$^{២}$ - ២០ម$^{២}$ | ៣០០០៛ | ២០០០៛ | ១៩៥០០០៛ | | | ២០០០០០៛ |
| | | ២០ម$^{២}$ ឡើង | ៣០០០៛ | ២០០០៛ | ៣៩៥០០០៛ | | | ៤០០០០០៛ |
| | -បដាផ្សាយពាណិជ្ជកម្ម | | ១០០០៛ | ២០០០៛ | ១២០០០៛ | ៣ខែ | លិខិតអនុញ្ញាត | ១៥០០០៛ |
| | -បណ្ណប្រកាសផ្សាយពាណិជ្ជកម្ម | | ១០០០៛ | ២០០០៛ | ១២០០០៛ | | | ១៥០០០៛ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥-សេវាកម្មស្លាកសញ្ញាអាជីវកម្ម | -ទីតាំងផលិតស្លាកសញ្ញា | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | -ជាងគំនូរ | ៣០០០៛ | ២០០០៛ | ២១០០០៛ | ១ឆ្នាំ | | ២៦០០០៛ |
| ៦-សេវាកម្មចម្លាក់ពុម្ព | -ទីតាំងផលិត លក់ចម្លាក់ពុម្ពស៊ីម៉ង់ | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | -ទីតាំងផលិតលក់ចម្លាក់ម្នាងសិលា | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | | | ៤០០០០៛ |
| ៧-សេវាកម្មលក់សៀវភៅ | -បណ្ណាគារ ( ខ្នាតធំ ) | ៣០០០៛ | ២០០០៛ | ៧៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៨០០០០៛ |
| | -បណ្ណាគារ | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | | | ៤០០០០៛ |
| | -តូបលក់សៀវភៅ | ៣០០០៛ | ២០០០៛ | ២១០០០៛ | | | ២៦០០០៛ |
| ៨-សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ | -សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ | ៣០០០៛ | ២០០០៛ | ២១០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ២៦០០០៛ |
| ៩-សេវាកម្មគ្រឿងបំពងសំឡេង | -សេវាកម្មជួលឧបករណ៍ឧគ្ឃោសនសព្ទក្នុងពិធីផ្សេងៗ | ៣០០០៛ | ២០០០៛ | ៣០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៨០០០៛ |
| | -សេវាកម្មជួលធុងបាស់ | ៣០០០៛ | ២០០០៛ | ៣០០០៛ | | | ៨០០០៛ |
| ១០-សេវាកម្មអ៊ុតសក់ កាត់សក់ លម្អក្រចក | -ហាងកាត់សក់ ( ២ - ៨កៅអី ) | ៣០០០៛ | ២០០០៛ | ១៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ២០០០០៛ |
| | -ហាងកាត់សក់ ( លើសពី៤ កៅអី ) | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | | | ៤០០០០៛ |
| | -ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក ( ២ -៨ កៅអី ) | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | | | ៤០០០០៛ |
| | -ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក ( លើសពី៨កៅអី ) | ៣០០០៛ | ២០០០៛ | ៥៥០០០៛ | | | ៦០០០០៛ |
| ១១-សេវាកម្មសម្អាងការ | -សម្អាងការ ( តម្លៃក្រោម ៥០០ ដុល្លា ) | ៣០០០៛ | ២០០០៛ | ៤៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៥០០០០៛ |
| | -សម្អាងការ ( តម្លៃក្រោម ១០០០ដុល្លា ) | ៣០០០៛ | ២០០០៛ | ៧៥០០០៛ | | | ៨០០០០៛ |
| | -សម្អាងការ ( តម្លៃលើសពី ១០០០ ដុល្លា ) | ៣០០០៛ | ២០០០៛ | ៩៥០០០៛ | | | ១០០០០០៛ |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១២

**តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**